# ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០១៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រត្ថតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

Downloaded from http://www.khmerlaws.com

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើត **រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ** មានអក្សរកាត់ថា " **រ.ប.វ.ត.** " មានឋានៈស្មើរដ្ឋលេខាធិការដ្ឋាន ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ហើយស្ថិតនៅក្រោមវិសាលភាពនៃបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៥១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

**មាត្រា ២.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានផ្នែកបច្ចេកទេស ស្ថិតក្រោមអាណាព្យាបាលរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និង ផ្នែកហិរញ្ញវត្ថុ ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ២
## បេសកកម្ម

**មាត្រា ៣.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានបេសកកម្មរៀបចំការប្រឡងប្រជែងជ្រើសរើស និង រៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងដល់សិស្សចៅក្រម និង សិស្សព្រះរាជអាជ្ញា ដែលបានជ្រើសរើសថ្មី ព្រមទាំងទទួលបន្ទុកបណ្តុះបណ្តាលបន្ត និងធ្វើវិក្រឹតការ ជូនដល់ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ដែលកំពុងបំពេញការីយកម្ម ។

**មាត្រា ៤.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវសហការល្អជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រសួងយុត្តិធម៌ សាលាជំរះក្តីនានា ក្នុងព្រះរាជាណាចក្រកម្ពុជា ស្ថាប័នតុលាការអន្តរជាតិ ព្រមទាំងស្ថាប័នពាក់ព័ន្ធនានា ដើម្បីរៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈជូនដល់ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ឱ្យឈានទៅជាបណ្តើរៗ រហូតមានកំរិតស្តង់ដារអន្តរជាតិ ។



3/7

Downloaded from http://www.khmerlaws.com

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**មាត្រា ៥.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- សាលាភូមិន្ទចៅក្រម
- សាលាភូមិន្ទក្រឡាបញ្ជី
- អគ្គលេខាធិការដ្ឋាន

## ជំពូកទី ៤
## តួនាទីភារកិច្ច

**មាត្រា ៦.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានតួនាទីភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការមេនៃការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម និងក្រឡាបញ្ជី
- រៀបចំ និងអនុម័តផែនការសកម្មភាពអភិវឌ្ឍន៍នៅក្នុងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- កំណត់បែបបទនៃការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម និង សិស្សក្រឡាបញ្ជី
- ទំនាក់ទំនងធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម និងក្រឡាបញ្ជី
- អនុម័តបទបញ្ជាផ្ទៃក្នុង
- អនុម័តគំរោងថវិកាប្រចាំឆ្នាំ
- រាយការណ៍ជូនទីស្តីការគណៈរដ្ឋមន្ត្រី តាមកាលកំណត់។

## ជំពូកទី ៥
## ការគ្រប់គ្រងរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

**មាត្រា ៧.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល និង ប្រធាននៃរ.ប.វ.ត.មួយរូប ហើយមានអគ្គលេខាធិការមួយរូប ទទួលបន្ទុកគ្រប់គ្រងរដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ ព្រមទាំងធ្វើឲ្យ និង សម្របសម្រួលការងាររវាងសាលាភូមិន្ទចៅក្រម និងសាលាភូមិន្ទក្រឡាបញ្ជី ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។



Downloaded from http://www.khmerlaws.com

ប្រធាននៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវជ្រើសរើសក្នុងចំណោមឥស្សរៈជនខ្មែរជាន់ខ្ពស់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានសញ្ញាប័ត្រខ្ពស់ផ្នែក នីតិសាស្ត្រ ឬ ផ្នែកគ្រប់គ្រង ។

អគ្គលេខាធិការនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ នាយកសាលាភូមិន្ទចៅក្រម និងនាយកសាលាភូមិន្ទក្រឡាបញ្ជីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨.-**

ក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវប្រជុំសាមញ្ញចំនួនបីដងក្នុងមួយឆ្នាំ ។ កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង ក្រសួងយុត្តិធម៌ ។

**មាត្រា ៩.-**

ក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានសមាសភាពដូចតទៅ:

| | |
|---|---|
| ១. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣. ប្រធាននៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ | សមាជិកស្វ័យប្រវត្តិ |
| ៤. តំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មួយរូប | សមាជិក |
| ៥. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយរូប | សមាជិក |
| ៦. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី មួយរូប | សមាជិក |
| ៧. តំណាងក្រសួងយុត្តិធម៌ មួយរូប | សមាជិក |
| ៨. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ មួយរូប | សមាជិក |
| ៩. ចៅក្រម តុលាការកំពូល មួយរូប | សមាជិក |
| ១០. ចៅក្រម សាលាឧទ្ធរណ៍ មួយរូប | សមាជិក |
| ១១. តំណាងអគ្គស្នងការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ មួយរូប | សមាជិក |
| ១២. នាយកសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ | សមាជិកអញ្ជើញ |
| ១៣. នាយកសាលាភូមិន្ទក្រឡាបញ្ជីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ | សមាជិកអញ្ជើញ |



Downloaded from http://www.khmerlaws.com

១៤. អគ្គលេខាធិការនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សមាជិកអញ្ជើញ

សមាជិកអញ្ជើញត្រូវបានអញ្ជើញឱ្យចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែពុំមានសិទ្ធិធ្វើការបោះឆ្នោតអនុម័តអ្វីឡើយ ។

សមាសភាពក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវតែងតាំងដោយអនុក្រឹត្យ ។

## ជំពូកទី ៦

## ធនធានហិរញ្ញវត្ថុ

**មាត្រា ១០.-**

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានថវិកាស្វយ័ត ដែលផ្គត់ផ្គង់ដោយថវិកាជាតិ ។ រ.ប.វ.ត. មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពផ្សេងៗ សំរាប់ការចំណាយលើដំណើរការបណ្តុះបណ្តាល សេវារដ្ឋបាល ផ្គត់ផ្គង់សំភារៈបរិក្ខារ និងការឧបត្ថម្ភផ្សេងៗ តាមការចាំបាច់ ក្នុងគោលដៅធានាប្រសិទ្ធភាពការងាររបស់ខ្លួន ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ១១.-**

ក្នុងកាលៈទេសៈចាំបាច់ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ អាចទទួលបន្ទុករៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការឯកទេសផ្សេងៗទៀត និងអ្នកជំនួយការតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៣.-**

សម្តេចនាយករដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមស្មារតីនៃព្រះរាជក្រឹត្យនេះ ។



Downloaded from http://www.khmerlaws.com

**មាត្រា ១៤.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ ២០០៥*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*៣រស.០៥០១-០២២*

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខា ព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ហត្ថលេខា**
**សុខ អាន**

លេខ [illegible] ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មករា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
[illegible]

***កន្លែងទទួល :***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- លេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង និង ស្ថាប័នរដ្ឋ
- ឯកសារ- កាលប្បវត្តិ



Downloaded from http://www.khmerlaws.com